ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តព្រៃវែង
លេខ ០០៥ សខព/១១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រមូលពន្ធលើអចលនទ្រព្យ

## អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

## ជំរាបមក

ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាម្ចាស់កម្មសិទ្ធិ មានអចលនទ្រព្យស្ថិតនៅក្នុងសង្កាត់កំពង់លាវ សង្កាត់ជើងទឹក និងសង្កាត់បារាយណ៍ ក្រុងព្រៃវែង ខេត្តព្រៃវែង ជ្រាបថា៖

ដោយអនុលោមតាមប្រកាសលេខ ៩៩៣ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ។

សាលាខេត្តព្រៃវែង សូមគោរពអញ្ជើញ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យ មកកាន់សាខាពន្ធដារខេត្តព្រៃវែង ដើម្បីចុះបញ្ជី និងដាក់លិខិតប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ .................. ឲ្យបានចប់សព្វគ្រប់នៅថ្ងៃទី ............. ខែ.................. ឆ្នាំ .....................។

ការមិនចុះបញ្ជី ការបង់ពន្ធខ្វះ ការបង់ពន្ធយឺត ឬមិនបានដាក់លិខិតប្រកាសពន្ធ ត្រូវរងទោសទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ។

សាលាខេត្តព្រៃវែង សូមបញ្ជាក់ថា ចំណូលពន្ធដែលបានមកពីពន្ធលើអចលនទ្រព្យ ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត-ក្រុង-ស្រុក-ខ័ណ្ឌ-ឃុំ-សង្កាត់) សម្រាប់អភិវឌ្ឍមូលដ្ឋាន។

សាលាខេត្តព្រៃវែង សង្ឃឹមនិងជឿជាក់ថា ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាកម្មសិទ្ធិករ ពិតជាយកចិត្តទុកដាក់បំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋជាពុំខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុង_សាមី**

**<u>កន្លែងទទួល៖</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដី
- គណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  ( គោរពជូនជ្រាប )
- អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត
- អភិបាលនៃគណៈអភិបាលក្រុងព្រៃវែង
- ក្រុមជំនួយការអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត
  ( ដើម្បីមុខការ )
- ឯកសារ-កាលប្បវត្តិ